ថែទាំកុមារក្នុងគ្រួសារ
ជាអាទិភាពចម្បង | REACT

# តោះ! ការពារខ្លួន ពេលប្រើអ៊ីនធឺណិត



សហការគាំទ្រដោយ

សហភាពអឺរ៉ុប

USAID
ជំនួយពីពលរដ្ឋអាមេរិក

GHR FOUNDATION

Save the Children

unicef


ស្របពេលដែលបច្ចេកទេសជឿនលឿន សុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធ អ៊ីនធឺណិតបានក្លាយជាប្រធានបទមួយ ដែលកុមារគ្រប់រូបត្រូវយល់ដឹង។


ហាសហ៉ា! ថ្ងៃនេះមានគេសុំរាប់អាន ក្នុងហ្វេសប៊ុកច្រើនណាស់!
អូ១! អ្នកណាខ្លះទៅបង? ខ្ញុំសុំមើលបន្តិចមក!


បងមិនស្គាល់ទេ! តែវាមិនមែនជារឿងរបស់ឯងទេតិរី។ កុំចង់ដឹងរឿងគេ!
មិនដែលមាន! បើមិនស្គាល់គ្នាផង ម៉េចបានគេមកសុំរាប់អានបងឯង?
ប្រហែលមកពីបងគួរឱ្យចូលចិត្ត ហើយមានគេនិយាយល្អៗពីបង បានជាមានគេមកសុំរាប់អានច្រើនបែបនេះ!




ចុះបើនៅខាងក្រៅ នៅសុខៗ ស្រាប់តែមានមនុស្សដើរតាមផ្លូវ មិនដែលស្គាល់មុខ មកសុំកូនឯងធ្វើមិត្តភក្តិ តើកូនឯងព្រមដែរ?
អ្នកណាទៅព្រមម៉ែ!
តាមហ្វេសប៊ុក និងបណ្តាញសង្គមនានា ក៏ដូចគ្នាដែរ! កូនមិនត្រូវចេះតែទទួលធ្វើជាមិត្តភក្តិជាមួយជនប្លែកមុខនោះទេ។ កូនត្រូវគិតឱ្យបានច្បាស់លាស់មុនពេលកូនចុចទទួល ការស្នើសុំជាមិត្ត...


មេរោគ
...ឬបើកមើល តំណរភ្ជាប់
ការផ្សាយពាណិជ្ជកម្ម រូបថត
និងវីដេអូនានា ព្រោះ យើងអត់
ដឹងទេថាវានឹងកើតរឿងអីខ្លះ!
ពេលខ្លះវាមានផ្ទុកមេរោគ ឬ
លួចយកព័ត៌មានពីទូរសព្ទកូន
ឯងទៀត!
មែនឬម៉ែ? តែមិត្តភក្តិកូនដូចជា
គ្មានអីផងម៉ែ! កូនឃើញគេ
ចែករំលែករូបថតមិត្តរបស់ពួកគេ។
មើលទៅដូចជាសប្បាយខ្លាំង
ណាស់ម៉ែ!




យើងមិនអាចភ្លេចខ្លួនទេកូន! ជនទុច្ចរិតដែលឃើញព័ត៌មានរបស់កូន អាចយកវា
ទៅប្រើប្រាស់ដើម្បី បោកបន្លំអ្នកដទៃ ឬមកគំរាមកំហែងកូនវិញក៏មាន។
កូនត្រូវការពារព័ត៌មានផ្ទាល់ខ្លួនឱ្យមានសុវត្ថិភាព នៅពេលកូននិយាយ
ឬសរសេរកូនមិនត្រូវបង្ហាញ ព័ត៌មានដូចជា...
...ឈ្មោះពេញ លេខសម្ងាត់ ឬអាសយដ្ឋាននោះទេ! កូនត្រូវចាំថា
ព័ត៌មានឯកជនរបស់កូនអាចមើលឃើញបានតាមរយៈរូបភាព
និងវីដេអូដែលកូនចែករំលែកផងដែរ។


ចុះមិត្តភក្តិកូនខ្លះគេស្គាល់គ្នាតាមអ៊ីនធឺណិត ហើយ
ណាត់ជួបគ្នាជជែកលេងនៅខាងក្រៅទៀតនោះ?
ទេៗកូន! វាគ្រោះថ្នាក់ខ្លាំងណាស់!
ព្រោះការណាត់ជួបនរណាម្នាក់
ដែលយើងស្គាល់តាមរយៈ
អ៊ីនធឺណិត ទោះបីជាមិត្តភក្តិរបស់
មិត្តយើងក៏ដោយ វាអាចបង្ក
គ្រោះថ្នាក់បាន...




...ដោយសារតែជននោះជាជនប្លែកមុខ!
ប្រសិនបើមានគេសុំជួប ឬសុំព័ត៌មាន
ផ្ទាល់ខ្លួន រូបថត ឬវីដេអូរបស់កូន
កូនត្រូវប្រាប់ដល់ពុកម៉ែភ្លាម!
មែនហើយពុកកូននិយាយត្រូវ!
តោះ! លាងដៃហើយហូបបាយ!
ម៉ែនឹងប្រាប់កូនបន្ថែមទៀត!
តោះលាងដៃ!



កូនៗមិនអាចទុកចិត្តបានលើអ្វីៗដែលកូនមើលឃើញតាមអ៊ីនធឺណិតនោះទេ ដោយសារតែព័ត៌មានខ្លះ មិនគ្រប់ជ្រុងជ្រោយ ឬមិនពិតតែម្តង








កូនអាចប្រាប់មនុស្សធំដែលកូនទុកចិត្តប្រសិនបើមានអ្វីមួយ ឬនរណាម្នាក់ដែលធ្វើឱ្យកូនមិនសប្បាយចិត្ត! វាអាចជាករណីដែលកូនឬបុគ្គលដែលកូនស្គាល់ត្រូវបានគេបៀតបៀន!






**សូមទាក់ទងទៅកាន់លេខ**

# ០៩២ ៣១១ ៥១១

**ដើម្បីរាយការណ៍ពីការរំលោភបំពានកុមារ**
**តាមអ៊ីនធឺណិត ទៅកាន់**
**បណ្ដាញរាយការណ៍ពិសេសតាមប្រព័ន្ធ**
**អ៊ីនធឺណិតកម្ពុជា**






ចេះការពារសុវត្ថិភាពព័ត៌មានផ្ទាល់ខ្លួន

មិនណាត់ជួបអ្នកដែលយើងស្គាល់តាមអនឡាញ





គិតពិចារណាមុននឹងទទួលយល់ព្រម
ធ្វើជាមិត្ត ឬបើកតំណរភ្ជាប់នានា

ផ្ទៀតផ្ទាត់ព័ត៌មានដែលពិត





និងប្រាប់ទៅមនុស្សធំពេលដែលកូនមាន
អារម្មណ៍មិនសុខស្រួល។












កុមារឆ្លាត ប្រើប្រាស់អ៊ីនធឺណិតដោយ**ឆ្លាតវៃ**
ដោយចេះការពារខ្លួន
និងស្វែងរកជំនួយដែលប្អូនទុកចិត្តបាន!




កុមារឆ្លាត ប្រើប្រាស់អ៊ិនធឺណិត
ដោយឆ្លាតវៃ ដោយចេះការពារខ្លួន និង
ស្វែងរកជំនួយដែលប្អូនទុកចិត្តបាន!